ពួកជំនុំ។ យើងនឹងយល់ខុស ប្រសិនបើយើងនឹកស្រមៃថា ជើងចង្កៀងនេះ ដូចជាជើងទៀនដែលយើងប្រើសព្វថ្ងៃ ដែលមានទៀនក្រមួនដោតជាប់នៅលើទ្រនាប់។ នៅក្នុងរោងឧបោសថ "ចង្កៀង" ទាំងនោះគឺជាចានតូចៗ ដែលមានផ្លូវសម្រាប់ដាក់ប្រេង។ គេដាក់ខ្សែប្រឆេះតូចៗ ក្នុងប្រេង ហើយពន្លឺកើតឡើង ដោយការដុតខ្សែរនោះ ដែលធ្វើឲ្យប្រេងនៅក្នុងខ្សែរប្រឆេះនោះឆេះឡើង។ ប្រសិនបើគ្មានប្រេងនៅក្នុងចង្កៀងទេ ឬប្រសិនបើប្រេងនោះមិនត្រូវបានដុតឲ្យឆេះទេ នោះចង្កៀងនឹងមិនបញ្ចេញពន្លឺឡើយ។ នៅក្នុងទីបរិសុទ្ធ ជើងចង្កៀងគឺជាប្រភពតែមួយគត់នៃពន្លឺ។ ប្រសិនបើគ្មានពន្លឺចេញពីជើងចង្កៀងទេ នោះមិនមានពន្លឺអ្វីឡើយ។

តើអ្នកឃើញទេថា ការនេះដូចគ្នានឹងពួកជំនុំយ៉ាងដូចម្តេច? យើងក៏ជាពន្លឺតែមួយគត់ដែរ។ គ្មានពន្លឺផ្សេងទៀតទេ។ យើងគឺជាជើងចង្កៀងដែលមានមែកប្រាំពីរ។ យើងបញ្ចេញពន្លឺបាន លុះត្រាតែយើងពេញដោយប្រេង ហើយប្រេងនៅក្នុងយើងត្រូវបានដុតឲ្យឆេះ។

នៅក្នុងព្រះគម្ពីរ ប្រេងតែងតែជានិមិត្តរូបនៃព្រះវិញ្ញាណបរិសុទ្ធ។ និមិត្តរូបនេះបង្ហាញថា ពួកជំនុំអាចបញ្ចេញពន្លឺបាន លុះត្រាតែពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងត្រូវបានព្រះបញ្ឆេះឲ្យឆេះប៉ុណ្ណោះ។

គោលបំណងចម្បងរបស់យើង

មុខងាររបស់ជើងចង្កៀង គឺបញ្ចេញពន្លឺទៅលើវត្ថុដែលស្ថិតនៅទល់មុខវាដោយផ្ទាល់ គឺតុមាសសម្រាប់តម្កល់នំប៉័ងថ្វាយព្រះនៅក្នុងទីបរិសុទ្ធ។ ជាការពិតណាស់ នំប៉័ងថ្វាយព្រះ តំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ដែលបានមានបន្ទូលថា៖

ខ្ញុំជានំប៉័งជីវិត... ខ្ញុំជានំប៉័งដ៏រស់ ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័งនេះ នោះនឹងរស់នៅអស់កល្បជានិច្ច ឯនំប៉័ងដែលខ្ញុំឲ្យ គឺជារូបសាច់ខ្ញុំ ដែលខ្ញុំនឹងឲ្យជំនួសជីវិតមនុស្សលោក។

(យ៉ូហាន 6:48, 51)

គោលបំណងទាំងមូលរបស់ជើងចង្កៀង គឺធ្វើកិច្ចការតែមួយគត់៖ បញ្ចេញពន្លឺទៅលើតុនំប៉័ងថ្វាយព្រះ។ នេះក៏ជាការពិតផងដែរ សម្រាប់ពួកជំនុំរបស់ព្រះយេស៊ូវគ្រីស្ទ។ យើងនៅលើផែនដីនេះ ដើម្បីគោលបំណងតែមួយគត់៖ គឺបញ្ចេញពន្លឺទៅលើព្រះយេស៊ូវ ដែលជានំប៉័ងនៃជីវិត។ ហើយយើងអាចធ្វើដូច្នេះបាន លុះត្រាតែយើងពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងត្រូវបានដុតបញ្ឆេះដោយភ្លើងរបស់ទ្រង់។

នៅទីនេះ យើងឃើញរូបភាពដ៏គួរឲ្យកត់សម្គាល់មួយអំពីពួកជំនុំ។ ក្រៅពីជើងចង្កៀង គ្មានប្រភពពន្លឺណាមួយនៅក្នុងទីបរិសុទ្ធឡើយ។ ក្រៅពីពួកជំនុំ ក៏គ្មានពន្លឺណាមួយនៅក្នុងលោកិយដែរ។ ដូចជាជើងចង្កៀងអាចបញ្ចេញពន្លឺបាន លុះត្រាតែវាពេញដោយប្រេង និងត្រូវបានដុតឲ្យឆេះ ពួកជំនុំក៏អាចបញ្ចេញពន្លឺបាន លុះត្រាតែពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងត្រូវបានបញ្ឆេះឲ្យឆេះដែរ។

ជើងចង្កៀងមានវត្ថុតែមួយគត់ដែលវាត្រូវបញ្ចេញពន្លឺទៅលើ គឺតុនំប៉័ងថ្វាយព្រះ។ ពួកជំនុំក៏មាន "អង្គ" តែមួយគត់ដែលត្រូវបញ្ចេញពន្លឺទៅលើដែរ គឺព្រះអម្ចាស់យេស៊ូវ។

មូលហេតុតែមួយគត់ដែលអ្នក និងខ្ញុំ ជាគ្រីស្ទបរិស័ទ នៅលើផែនដីនេះ គឺដើម្បីបញ្ចេញពន្លឺទៅលើព្រះយេស៊ូវគ្រីស្ទ ដែលជានំប៉័ងនៃជីវិត។ នេះគឺជាគោលបំណងចម្បងនៃវត្តមានរបស់យើងនៅលើផែនដី។ អ្វីៗផ្សេងទៀតដែលយើងអាចធ្វើបាន គឺស្ថិតនៅលំដាប់បន្ទាប់ពីនេះ។ យើងគឺជាពន្លឺនៃលោកីយ៍។ ឥឡូវនេះ ចូរយើងទូលសូមព្រះអម្ចាស់ ឲ្យជួយយើងបំពេញគោលបំណងដែលទ្រង់មានសម្រាប់យើង៖

ព្រះអម្ចាស់យេស៊ូវអើយ! យើងខ្ញុំសូមចូលមកនៅចំពោះព្រះវត្តមានទ្រង់។ សូមបំពេញយើងខ្ញុំជាថ្មីម្តងទៀត ដោយប្រេងនៃព្រះវិញ្ញាណបរិសុទ្ធ ហើយសូមបញ្ឆេះយើងខ្ញុំផង ដើម្បីឲ្យពន្លឺរបស់យើងខ្ញុំបានភ្លឺឡើង។ យើងខ្ញុំប្តេជ្ញាចិត្តក្នុងការបើកបង្ហាញព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទៅកាន់ពិភពលោកជុំវិញយើងខ្ញុំ ដោយឆ្លុះបញ្ចាំងពីសិរីល្អរបស់ទ្រង់ តាមរបៀបដែលនឹងទាក់ទាញមនុស្សជាច្រើនឲ្យមករកទ្រង់។

អាម៉ែន

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សម្រាប់ការបង្រៀនបន្ថែមអំពីប្រធានបទនេះ សូមចូលទៅកាន់គេហទំព័ររបស់យើង៖
www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ISSUE #095

លោក ដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ការរស់នៅជាអំបិល និងពន្លឺ

ផ្នែកទី ១៖ ពន្លឺនៃលោកីយ៍

នៅទូទាំងពិភពលោក ប្រជាជាតិនានាកំពុងប្រឈមមុខនឹងវិបត្តិជាច្រើនប្រភេទ។ ក្នុងការបំពេញគោលបំណងដែលព្រះបានកំណត់សម្រាប់យើងជាប្រជារាស្ត្ររបស់ព្រះ យើងមានតួនាទីដ៏សំខាន់មួយ ក្នុងការធ្វើជាអំបិល និងជាពន្លឺ ដើម្បីនាំមកនូវការផ្លាស់ប្តូរដែលត្រូវការនៅក្នុងប្រជាជាតិរបស់យើង។

នៅក្នុងសេចក្តីផ្តើមនៃសៀវភៅដ៏មានឥទ្ធិពលក្នុងស៊េរីមេរៀននេះ ដែលមានចំណងជើងថា "ការរស់នៅជាអំបិល និងជាពន្លឺ" លោក ដេរេក ព្រីនស៍ បានសរសេរថា៖

"ខ្ញុំជឿជាក់យ៉ាងមុតមាំថា ប្រទេសរបស់យើងត្រូវការការផ្លាស់ប្តូរ ហើយក៏អាចត្រូវបានផ្លាស់ប្តូរបានផងដែរ... ហើយយើងហ្នឹងហើយ គឺជាមនុស្សដែលត្រូវនាំមកនូវការផ្លាស់ប្តូរនោះ។ គោលបំណងរបស់ខ្ញុំ គឺបង្ហាញអ្នកពីព្រះបន្ទូលរបស់ព្រះ អំពីរបៀបដែលយើងអាចសម្រេចកិច្ចការនេះបាន។"

គោលបំណងដែលបានលើកឡើងខាងលើនេះ នឹងក្លាយជាចំណុចផ្តោតសំខាន់នៃសេចក្តីបង្រៀន **ការរស់នៅជាអំបិល និងពន្លឺ** ដែលមាន ៣ ភាគ។ នៅក្នុងភាគទី ១ យើងនឹងពិនិត្យមើលនូវអត្ថន័យនៃព្រះបន្ទូលដែលព្រះយេស៊ូវមានបន្ទូលថា៖ ***"អ្នករាល់គ្នាជាពន្លឺនៃលោកីយ៍"*** (ម៉ាថាយ 5:14)។

ពន្លឺនៃលោកីយ៍

សេចក្តីអធិប្បាយនៅលើភ្នំ ត្រូវបានគ្រីស្ទបរិស័ទទូទាំងពិភពលោកទទួលស្គាល់ថា ជាមាត្រដ្ឋាននៃជំនឿ និងការរស់នៅ ដែលព្រះយេស៊ូវបានកំណត់សម្រាប់អ្នកជឿពិតប្រាកដទាំងអស់។ វាមិនមែនជាសារពិសេស សម្រាប់តែអ្នកដែលមានតួនាទីជាអ្នកដឹកនាំ ដូចជា គ្រូបង្រៀន សាវ័ក ហោរា អ្នកផ្សាយដំណឹងល្អ ឬអ្នកអធិប្បាយប៉ុណ្ណោះនោះទេ។ ផ្ទុយទៅវិញ នៅក្នុងបទគម្ពីរនេះ ព្រះយេស៊ូវបានបើកសម្តែងពីព្រះហឫទ័យរបស់ព្រះ និងខ្នាតស្តង់ដារដែលព្រះបានកំណត់ សម្រាប់គ្រីស្ទបរិស័ទស្មោះត្រង់គ្រប់រូប។

សម្រាប់បទគម្ពីរដំបូងរបស់យើង ខ្ញុំសូមលើកយកព្រះបន្ទូលរបស់ព្រះយេស៊ូវនៅក្នុង គម្ពីរម៉ាថាយ 5:13–14 មកពិចារណា៖

> *អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ អ្នករាល់គ្នាជាពន្លឺនៃលោកីយ ឯទីក្រុងណាដែលនៅលើភ្នំ នោះលាក់មិនកំបាំងទេ។*

ដោយមានបន្ទូលទៅកាន់គ្រីស្ទបរិស័ទទាំងអស់ ព្រះយេស៊ូវបានប្រាប់យើង អំពីការពិតដ៏សំខាន់បីយ៉ាងអំពីខ្លួនយើង គឺ៖ 1) យើងជាអំបិលនៃផែនដី 2) យើងជាពន្លឺនៃលោកីយ៍ 3) យើងជាទីក្រុងដែលស្ថិតលើភ្នំ ដែលលាក់មិនកំបាំង។ ជាការណែនាំចូលទៅកាន់ប្រធានបទនេះ ខ្ញុំចង់បង្ហាញពីអត្ថន័យ និងផលប៉ះពាល់ជាក់ស្តែងមួយចំនួន ដែលកើតចេញពីសេចក្តីថ្លែងការណ៍ទាំងបីនេះ។ យើងនឹងពិចារណាវាតាមលំដាប់បញ្ច្រាសពីរបៀបដែលព្រះយេស៊ូវបានមានបន្ទូល ដោយចាប់ផ្តើមនៅក្នុងភាគនេះជាមួយនឹងតួនាទីពីរចុងក្រោយ ដែលទ្រង់បានប្រទានឲ្យយើង ។ នៅក្នុងភាគបន្ទាប់ យើងនឹងពិភាក្សាអំពីសេចក្តីថ្លែងការណ៍ដំបូង។

គ្រីស្ទបរិស័ទដែលគេគ្រប់គ្នាមើលឃើញ

ជាដំបូង យើងគឺជា «ទីក្រុងណាដែលនៅលើភ្នំ នោះលាក់មិនកំបាំងទេ» (ម៉ាថាយ 5:14)។ ការពិតនេះអនុវត្តចំពោះមនុស្សគ្រប់រូបដែលប្រកាសជាសាធារណៈអំពីជំនឿលើព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់។ នៅពេលដែលអ្នកប្រកាសជំនឿនោះជាសាធារណៈ អ្នកក្លាយជាទីក្រុងមួយដែលស្ថិតនៅលើភ្នំភ្លាម។ អ្នកមិនអាចលាក់បាំងបានឡើយ។

អ្នកនឹងក្លាយជាមនុស្សដែលគេចាប់អារម្មណ៍មើល។ មនុស្សគ្រប់ទិសទី នឹងសម្លឹងមកអ្នកគ្រប់ពេលវេលា មិនថាអ្នកកំពុងរៀននៅសាលា ឬកំពុងធ្វើការនៅក្នុងរោងចក្រ ឬនៅការិយាល័យនោះទេ។ ពួកគេនឹងសង្កេតមើលអ្នក ដើម្បីដឹងថា តើភាពជាគ្រីស្ទបរិស័ទរបស់អ្នកពិតប្រាកដឬអត់។ តើអ្នកដែលកំពុងសង្កេតមើលអ្នក នឹងសួរខ្លួនឯងអ្វីខ្លះអំពីអ្នក? តើជំនឿរបស់អ្នកពិតប្រាកដឬទេ? តើអ្នកពិតជាជឿលើអ្វីដែលអ្នកអះអាងថាជឿឬទេ? តើអ្នករស់នៅស្របតាមជំនឿនោះដែរឬទេ?

មនុស្សនឹងពិនិត្យមើលគ្រប់ផ្នែកនៃជីវិតរបស់អ្នក ដូចជា ជីវិតគ្រួសារ ជីវិតការងារ ជីវិតសង្គម និងផ្នែកផ្សេងៗទៀត។ ពួកគេក៏នឹងពិនិត្យមើលការប្រព្រឹត្ត និងទីបន្ទាល់របស់ពួកជំនុំដែលអ្នកចូលរួមផងដែរ។ ក្នុងករណីភាគច្រើន ពួកគេនឹងវិនិច្ឆ័យអំពីគ្រីស្ទបរិស័ទដោយផ្អែកលើអ្វីដែលពួកគេឃើញនៅក្នុងអ្នក។ អ្នកគឺជាទីក្រុងមួយដែលស្ថិតនៅលើភ្នំ។

នៅពេលដែលខ្ញុំជាគ្រីស្ទបរិស័ទវ័យក្មេង ក្នុងពួកជំនុំអង់គ្លីខិន ដ៏ធំអស្ចារ្យក្នុងប្រទេសអង់គ្លេស ខ្ញុំបានឃើញថា ភាពជាគ្រីស្ទបរិស័ទ គឺជាការបរាជ័យ។ ខ្ញុំបានបង្កើតនូវផ្នត់គំនិតនេះ ដោយមើលទៅលើមនុស្សជុំវិញខ្ញុំ ហើយសន្និដ្ឋានថា តើពួកគេពិតជាជឿអ្វីដែលពួកគេកំពុងប្រកាសថា ពួកគេជឿនោះឬទេ?

ដូច្នេះ អ្នកត្រូវតែដឹងថា នៅពេលដែលអ្នកប្រកាសជំនឿលើព្រះយេស៊ូវគ្រីស្ទ អ្នកនឹងក្លាយជាមនុស្សដែលគេចាប់អារម្មណ៍មើលភ្លាម។ អ្នកមិនអាចគេចផុតពីការពិតនេះបានឡើយ។ ប្រសិនបើអ្នកមិនចង់ឲ្យគេចាប់អារម្មណ៍មើល មិនចង់ឲ្យគេសង្កេតមើលវិនិច្ឆ័យ និងពិនិត្យអ្នកទេ នោះកុំប្រកាសជំនឿលើព្រះយេស៊ូវគ្រីស្ទ។ ប៉ុន្តែ ប្រសិនបើអ្នកប្រកាសជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះស្ថានភាពរបស់អ្នកនឹងទៅជាបែបនេះ៖ មនុស្សនឹងចាប់ផ្តើមសង្កេតមើលអ្នក។ ចាប់ពីពេលនោះតទៅ អ្នកនឹងក្លាយជាទីក្រុងមួយដែលស្ថិតនៅលើភ្នំ ដែលមិនអាចលាក់បាំងបានឡើយ។

ភ្នាននពន្លឺផ្សេងទៀតទេ

ទីពីរ ព្រះយេស៊ូវមានបន្ទូលថា៖ *"អ្នករាល់គ្នាជាពន្លឺនៃលោកីយ៍"* (ម៉ាថាយ 5:14)។ នៅក្នុងពេលវេលា និងទីកន្លែងផ្សេងៗគ្នានៃជីវិតរបស់ខ្ញុំ ខ្ញុំធ្លាប់ជាគ្រូបង្រៀនភាសាអង់គ្លេស។ ខ្ញុំយល់ភាសាអង់គ្លេសបានគ្រប់គ្រាន់ដើម្បីដឹងថា នៅពេលដែលព្រះគម្ពីរចែងថា *"អ្នករាល់ជាពន្លឺនៃលោកីយ៍"* នោះមានន័យថាយើងគឺជាពន្លឺ។ និយាយម្យ៉ាងទៀត គ្មានពន្លឺផ្សេងទៀតទេ។ ពាក្យ "the" ដែលប្រើនៅទីនេះ មានន័យច្បាស់លាស់ថា មានតែមួយប៉ុណ្ណោះ។ យើងគឺជាពន្លឺតែមួយគត់។

ព្រះយេស៊ូវបានមានបន្ទូលថា៖ *"កាលខ្ញុំកំពុងតែនៅក្នុងលោកីយនៅឡើយ នោះខ្ញុំជាពន្លឺនៃលោកីយ៍"* (យ៉ូហាន 9:5)។ ប៉ុន្តែ ឥឡូវនេះ ទ្រង់មិនគង់នៅក្នុងលោកិយ ដោយរូបកាយទៀតទេ ហើយយើងគឺជាតំណាងរបស់ទ្រង់។ ដូច្នេះ តំណាងព្រះអង្គ យើងជាពន្លឺនៃលោកីយ៍។ ប្រសិនបើយើងមិនបញ្ចេញពន្លឺទេ នោះគ្មានប្រភពពន្លឺផ្សេងទៀតដែលលោកិយអាចងាកទៅរក ឬស្វែងរកពន្លឺពីនោះបានឡើយ។ នេះមានន័យថា លោកិយពឹងផ្អែកទាំងស្រុងលើគ្រីស្ទបរិស័ទ សម្រាប់ពន្លឺ។

ប្រេងស្រស់

មានឧទាហរណ៍សាមញ្ញមួយក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបង្ហាញយើងអំពីសារៈសំខាន់របស់យើង ក្នុងនាមជាពន្លឺនៃលោកីយ៍។ នៅក្នុងរោងឧបោសថដែលព្រះបានបង្គាប់ឲ្យលោកម៉ូសេសាងសង់ មានបន្ទប់ពីរ។ បន្ទប់ទីមួយហៅថា ទីបរិសុទ្ធ ហើយបន្ទប់ទីពីរហៅថា ទីបរិសុទ្ធបំផុត។ នៅក្នុងទីបរិសុទ្ធ មានគ្រឿងសង្ហារឹមតែបីមុខប៉ុណ្ណោះ ហើយមួយក្នុងចំណោមនោះ គឺជាជើងចង្កៀងដែលមានមែកប្រាំពីរ។

នៅក្នុងព្រះគម្ពីរ ជើងចង្កៀងតែងតែតំណាងឲ្យ

